ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ៧៦៤
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨
សាលក្រមលេខ ៦៥ (ម)
ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០

តាងនាមប្រជារាស្ត្រខ្មែរ
**សាលាដំបូងខេត្តកណ្តាល**
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
**នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០**
ដោយមានសមាសភាព៖

-លោក [redacted] ចៅក្រម
-លោក [redacted] ក្រឡាបញ្ជី

-សហដើមចោទ៖

ក.ឈ្មោះ [redacted] **អុល** ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] **ស៊ីថា** អាយុ៥០ឆ្នាំ ទីលំនៅបច្ចុប្បន្ន [redacted]។

ខ.ឈ្មោះ [redacted] **គឹម** ភេទប្រុស អាយុ៦០ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] **ទូច** ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]។

គ.ឈ្មោះ [redacted] **ហ៊ិន** ភេទប្រុស អាយុ៥៧ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] **អ៊ីម** ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]។

-មេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទលោកស្រី [redacted]។

-អ្នកជំនួយការ គ្មាន។

-អ្នកបកប្រែភាសា គ្មាន។

-ចុងចម្លើយឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅភូមិ [redacted]។

-មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយលោក [redacted]។

-អ្នកជំនួយការ គ្មាន។

-អ្នកបកប្រែភាសា គ្មាន។

**អង្គហេតុ និងចំណុចវិវាទ**

**១.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយសហដើមចោទ៖**

ក.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុខុម ផ្ទេរសិទ្ធិកាន់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ



Scanned with CamScanner

១២២៤/១៧ ទ.ព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួលទំហំ ១៤.៣៦៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល មកឲ្យសហដើមចោទឈ្មោះ [redacted] អុល និងប្រពន្ធឈ្មោះ [redacted] ស៊ីថា វិញ ។

ខ.បង្គាប់ឲ្យចុងចម្លើយ [redacted] សុខុន ផ្ទេរសិទ្ធិកាន់កាប់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១២៣០/១៧ ទ.ព ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួលទំហំ ១៨.៣៣៧ ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល មកឲ្យសហដើមចោទឈ្មោះ [redacted] គឹម និងប្រពន្ធឈ្មោះ [redacted] ទូច វិញ ។

គ.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុខុន ផ្ទេរសិទ្ធិកាន់កាប់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១៥៩១/១៧ ទ.ព ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួលទំហំ ១៥.៨៥៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល មកឲ្យសហដើមចោទឈ្មោះ ឌី ហ៊ាន និងប្រពន្ធឈ្មោះ [redacted] អ៊ីម វិញ ។

ឃ.រំលាយកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] សុវណ្ណឌឿន (តំណាងឲ្យទាំង៣គ្រួសារ) ជាមួយនិងឈ្មោះ [redacted] ប៊ុនធឿន (តំណាងឲ្យឈ្មោះ [redacted] សុខុន) ។

ង.សងសោហ៊ុយមេធាវី និងជម្ងឺចិត្តចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល ។

ច.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី:**

កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] សុវណ្ណឌឿន (តំណាងឲ្យសហដើមចោទទាំងបីគ្រួសារ) បានចុះកិច្ចសន្យាលក់ដី ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ទំហំ ៤០.០០០ (បួនម៉ឺន) ម៉ែត្រក្រឡា (ស្មាន) ឲ្យទៅឈ្មោះ [redacted] ប៊ុនធឿន (តំណាងឲ្យឈ្មោះ [redacted] សុខុន) ក្នុងតម្លៃ ៥,៥ ដុល្លារអាមេរិក ក្នុង០១ម៉ែត្រក្រឡា និងបានកក់ប្រាក់លើកទី១ ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក និងលើកទី២ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ កក់ប្រាក់ចំនួន ២១.០០០ (ពីរម៉ឺនមួយពាន់) ដុល្លារអាមេរិក និងបានឯកភាពឲ្យភាគីអ្នកទិញដីឈូសឆាយដីព្រៃក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃ ទើបកក់ប្រាក់បន្ថែមចំនួន ៣៥.០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដើម្បីធ្វើប្លង់ត្រឹមឃុំ រហូតដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ និងប្រគល់ប្រាក់គ្រប់ចំនួនទាំងអស់ ។ ក្រោយមកសហដើមចោទទាំងបីគ្រួសារបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១២២៤/១៧ទព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧, លេខ ១២៣០/១៧ទព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ និងលេខ ១៥៩១/១៧ទព ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ឲ្យទៅឈ្មោះ [redacted] សុខុន ។ លុះដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] សុខុន មិនបានប្រគល់ប្រាក់បង្គ្រប់ថ្លៃដីនោះទេ រហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ទើបប្រគល់ប្រាក់ឲ្យចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ។ បន្ទាប់មកទៀតនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ឈ្មោះ [redacted] សុខុន បានប្រគល់ប្រាក់ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិកបន្ថែមទៀត និងបានធ្វើកិច្ចសន្យាថានៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ និងប្រគល់ប្រាក់ថ្លៃដីឲ្យគ្រប់ចំនួន បើមិនគោរពតាមកិច្ចសន្យានេះទេ ឈ្មោះ [redacted] សុខុន យល់ព្រមយកប្លង់ដីដែលបានផ្ទេរសិទ្ធិរួច យកមកប្រគល់ឲ្យម្ចាស់ដីវិញ និងយល់ព្រមឲ្យអាជ្ញាធរឃុំ និងស្រុក មោឃភាពលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីខ្លីដោយគ្មានការតវ៉ា រីឯប្រាក់កក់កន្លងមកទុកជាអាសាបង់ ។ នៅពេលដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ឈ្មោះ ឡាច សុខុន មិនគោរពតាមកិច្ចសន្យានោះទេ និងបានគេចវេសមិនចូលខ្លួនដោះស្រាយនោះទេ ។ ទើបសហដើមចោទដាក់ពាក្យបណ្តឹងមកតុលាការតែម្តង ។



Scanned with CamScanner

៣.ការអះអាងរបស់ភាគី:

៣/១.លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទបានអះអាងថា ៖ នាងខ្ញុំរក្សាការទាមទារដូចក្នុងខ្លឹមសារនៃសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ទុកជាបានការដដែល ។ ដោយសារកាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ឈ្មោះ [redacted] **ម៉ាប់** និងឈ្មោះ [redacted] **សុវណ្ណខឿន** (តំណាងឲ្យសហដើមចោទទាំងបីគ្រួសារ) បានចុះកិច្ចសន្យាលក់ដី ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ទំហំ ៤០.០០០ (បួនម៉ឺន) ម៉ែត្រក្រឡា (ស្មាន) ឲ្យទៅឈ្មោះ [redacted] **ប៊ុនធឿន** (តំណាងឲ្យឈ្មោះ [redacted] **សុខុន**) ក្នុងតម្លៃ ៥,៥ ដុល្លាអាមេរិក ក្នុង០១ម៉ែត្រក្រឡា និងបានកក់ប្រាក់លើកទី១ ចំនួន ៣.០០០ (បីពាន់) ដុល្លាអាមេរិក និងលើកទី២ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ កក់ប្រាក់ចំនួន ២១.០០០ (ពីរម៉ឺនមួយពាន់ដុល្លាអាមេរិក) និងបានឯកភាពឲ្យភាគីអ្នកទិញដីឈូសឆាយដីព្រៃក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃ ទើបកក់ប្រាក់បន្ថែមចំនួន ៣៥.០០០ (បីម៉ឺនប្រាំពាន់) ដុល្លាអាមេរិក ដើម្បីធ្វើប្លង់ត្រឹមឃុំ រហូតដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ និងប្រគល់ប្រាក់គ្រប់ចំនួនទាំងអស់ ។ ក្រោយមកកូនក្តីរបស់ខ្ញុំទាំងបីគ្រួសារបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១២២៤/១៧ទព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧, លេខ ១២៣០/១៧ទព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ និងលេខ ១៥៩១/១៧ទព ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ឲ្យទៅឈ្មោះ [redacted] សុខុន ។ លុះដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] សុខុន មិនបានប្រគល់ប្រាក់បង្គ្រប់ថ្លៃដីនោះឲ្យកូនក្តីរបស់ខ្ញុំទេ រហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ទើបប្រគល់ប្រាក់ឲ្យកូនក្តីរបស់ខ្ញុំចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ។ បន្ទាប់មកទៀតនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ឈ្មោះ [redacted] សុខុន បានប្រគល់ប្រាក់ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) ដុល្លាអាមេរិកបន្ថែមទៀតឲ្យកូនក្តីរបស់ខ្ញុំ និងបានធ្វើកិច្ចសន្យាថានៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ និងប្រគល់ប្រាក់ថ្លៃដីឲ្យគ្រប់ចំនួន បើមិនគោរពតាមកិច្ចសន្យានេះទេ ឈ្មោះ [redacted] សុខុន យល់ព្រមយកប្លង់ដីដែលបានផ្ទេរសិទ្ធិរួច យកមកប្រគល់ឲ្យកូនក្តីរបស់ខ្ញុំជាម្ចាស់ដីវិញ និងយល់ព្រមឲ្យអាជ្ញាធរឃុំ និងស្រុក មោឃភាពលើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីដោយគ្មានការតវ៉ា រីឯប្រាក់កក់កន្លងមកទុកជាអាសាបង់ ។ នៅពេលដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ឈ្មោះ [redacted] សុខុន មិនគោរពតាមកិច្ចសន្យានោះទេ និងបានគេចវេសមិនចូល ខ្លួនដោះស្រាយជាមួយកូនក្តីរបស់ខ្ញុំនោះទេ ។ សរុបប្រាក់កូនក្តីខ្ញុំបានទទួលមានចំនួន ៩៧២.០០ (ប្រាំបួនម៉ឺនប្រាំពីរពាន់ពីររយ) ដុល្លារអាមេរិក នៅខ្វះចំនួន ១៦៩.៨៩៦ (ដប់ប្រាំមួយម៉ឺនប្រាំបួនពាន់ប្រាំបីរយកៅសិបប្រាំមួយ) ដុល្លាររាមេរិក ។ ក្នុងនាមខ្ញុំជាមេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទ នាងខ្ញុំសូមសំណូមពរឲ្យតុលាការចេញសាលក្រមសម្រេច ទី១.រំលាយកិច្ចសន្យាទិញ-លក់ដីចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] **ម៉ាប់** និងឈ្មោះ [redacted] **វណ្ណាខឿន** (តំណាងឲ្យកូនក្តីខ្ញុំទាំងបីគ្រួសារ) និងឈ្មោះ [redacted] **ប៊ុនធឿន** (តំណាងឲ្យឈ្មោះ [redacted] សុខុន) ចោល ។ ទី២.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **សុខុន** ប្រគល់ដីទំហំ ១៨.៣៣៧ (មួយម៉ឺនប្រាំបីពាន់បីរយសាមសិបប្រាំពីរ) ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ឲ្យទៅដើមចោទឈ្មោះ [redacted] **គីម** និងប្រពន្ធឈ្មោះ [redacted] **ទូច** វិញ ។ ប្រគល់ដីទំហំ ១៤.៣៦៨ (មួយម៉ឺនបួនពាន់បីរយហុកសិបប្រាំបី) ម៉ែត្រក្រឡា ឲ្យទៅដើមចោទឲ្យទៅដើមចោទឈ្មោះ [redacted] **អុល** និងប្រពន្ធឈ្មោះ [redacted] **ស៊ីថា** វិញ ។ និងប្រគល់ដីទំហំ ១៥.៨៥៨ (មួយម៉ឺនប្រាំពាន់ប្រាំបីរយហាសិបប្រាំបី) ម៉ែត្រក្រឡា ឲ្យទៅឈ្មោះ [redacted] **ហ៊ាន** និងប្រពន្ធឈ្មោះ [redacted] **អ៊ីម** វិញ ។ ទី៣.ទាមទារសំណងជំងឺចិត្ត និងសេវាកម្មផ្នែកច្បាប់ចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល ។

៣/២.លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានអះអាងថា ៖ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ឈ្មោះ [redacted] **ម៉ាប់** និងឈ្មោះ [redacted] **សុវណ្ណខឿន** នៅភូមិ [redacted]

[redacted]ជាប្អូនថ្លៃឈ្មោះ [redacted] ប៊ុនធឿន នៅភូមិ[redacted]បានចុះកិច្ចសន្យាទិញដី។ កិច្ចសន្យាបានព្រមព្រៀងគ្នាទិញដីប្រភេទដីចំការទំហំប្រមាណ ៤០០០០, (បួនម៉ឺន) ម៉ែត្រក្រឡា ក្នុងតម្លៃ ១ (មួយ) ម៉ែត្រក្រឡា ៥) ដុល្លារ៥,(ប្រាំកៀសប្រាំ) ដុល្លាអាមេរិក ។ ទ្វេរភាគីដែលបានចុះកិច្ចសន្យានេះ គឺជាភាគីទីផ្សារ និងស្វែងរកកប្រែជើងសារ ។ ក្រោយពីចុះកិច្ចសន្យា និងបានបង់ប្រាក់ទ្រនាប់ដៃរួចរាល់ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ភាគីម្ចាស់ដីដើមឈ្មោះ [redacted] អុល ឈ្មោះ [redacted] គីម និងឈ្មោះ [redacted] ហ៊ិន បានផ្តើមរៀបចំធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីទៅឲ្យឈ្មោះ [redacted] សុខុន ដែលជាកូនក្តីយើងខ្ញុំ គឺជាភាគីអ្នកទិញដីយ៉ាងពិតប្រាកដ ។

-នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលទ្រព្យដែលមិនទាន់ចុះបញ្ជីប្រភេទដីទួលដែលមានទំហំ ១៤ម៉ែត្រ ៣៦៨,ក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ពីឈ្មោះ [redacted] អុល និងប្រពន្ធឈ្មោះ [redacted] ស៊ីថា មានទីលំនៅនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ទៅឲ្យកូនក្តីយើងខ្ញុំឈ្មោះ [redacted] សុខុន ដោយបានឃើញ និងឯកភាពដោយមេឃុំទួលព្រេជ លេខ ១២២៤ទ ១៧/.ព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយអភិបាលស្រុកអង្គស្នួល លេខ ៨៩៨ចុះថ្ងៃទី ១៧/ខែឧ ៣១សភា ឆ្នាំ២០១៧ ។ ការផ្ទេរកម្មសិទ្ធិកាន់កាប់នេះ មានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួល ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ដែលបានឃើញ និងឯកភាពដោយសាលាឃុំទួលព្រេជផលដែរ ។

-នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីប្រភេទដីទួលដែលមានទំហំ ១៨ម៉ែត្រ ៣៣៧,ក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ពីឈ្មោះ [redacted] គីម និងប្រពន្ធឈ្មោះ [redacted] ទូច មានទីលំនៅនៅ[redacted] ទៅឲ្យកូនក្តីយើងខ្ញុំឈ្មោះ [redacted] សុខុន ដោយបានឃើញ និងឯកភាពដោយមេឃុំទួលព្រេជ លេខ ១២៣០/១៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយអភិបាលស្រុកអង្គស្នួល លេខ១៨៥៥បផ ១៧/២០១៧ខែកក្កដា ឆ្នាំ ២៨ចុះថ្ងៃទី ។ ការផ្ទេរសិទ្ធិកាន់កាប់នេះ ដោយមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួល ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ដែលបានឃើញ និងឯកភាពដោយសាលាឃុំទួលព្រេជផងដែរ ។

-នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាន់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជីប្រភេទដីទួលដែលមានទំហំ ១៥ម៉ែត្រ ៨៥៨,ក្រឡា ដែលមានទីតាំងស្ថិតនៅភូមត្រពាំងកំភ្លាញ់ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ពីឈ្មោះ [redacted] ហ៊ិន និងប្រពន្ធឈ្មោះ [redacted] អ៊ីម មានទីលំនៅនៅ[redacted] ទៅឲ្យកូនក្តីយើងខ្ញុំឈ្មោះ [redacted] សុខុន ដោយបានឃើញ និងឯកភាពដោយមេឃុំទួលព្រេជ លេខ ១៥៩១.ទ ១៧/ព ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយអភិបាលស្រុកអង្គស្នួល លេខ ១៤៨៧២០១៧ខែកក្កដា ឆ្នាំ ១១បផ ចុះថ្ងៃទី ១៧/ ។ ការផ្ទេរសិទ្ធិកាន់កាប់នេះ ដោយមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួល ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ដែលបានឃើញ និងឯកភាពដោយសាលាឃុំទួលព្រេជផងដែរ ។



Scanned with CamScanner

-ក្រោយពីបានចុះកិច្ចសន្យា និងទទួលបានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យខាងលើ កូនក្តីយើងខ្ញុំបានរៀបចំបែងចែកជាប្លង់ ពុះជាដីឡូត៍លក់ ដោយមានអតិថិជនមកកក់ទិញដី និងបង់រំលោះជាបន្តបន្ទាប់រហូតមក ចាប់ពីខែឧសភា ឆ្នាំ២០១៧ ។ ការទិញលក់ដីឡូត៍ ដោយបានចេញប្លង់ត្រឹមត្រូវ និងទទួលស្គាល់ដោយអភិបាលស្រុកអង្គស្នួល ហើយបានបង់ពន្ធដាត្រឹមត្រូវ នៅការិយាល័យសុរិយោដីស្រុកអង្គស្នួលផងដែរ រហូតមកដល់នៅអំឡុងខែសីហា មានអតិថិជនប្រមាណជាង ២០០នាក់ បានទិញដីឡូត៍នេះ ។

-នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] **ហ៊ុល** ដែលតំណាងឲ្យកូនក្តីយើងខ្ញុំឈ្មោះ [redacted] **សុខុន** បានប្រគល់ប្រាក់ទៅឲ្យឈ្មោះ [redacted] **សុវណ្ណឌឿន** ដែលតំណាងឲ្យម្ចាស់ដីឈ្មោះ [redacted] **គីម** ឈ្មោះ [redacted] **ហ៊ាន** និងឈ្មោះ [redacted] **អុល** នូវទឹកប្រាក់ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ។

ក្រោយមក ដោយសារតែការប្រែប្រួលខ្លះៗនៃការអនុវត្តកិច្ចសន្យាក្នុងការបង់ប្រាក់ជូនម្ចាស់ដី ([redacted] **គីម**, [redacted]**ហាន** និ[redacted] **អូល**) ពេលនោះ នៅរំឡុងខែសីហា ឆ្នាំ២០១៧ ក៏មានសកម្មភាពដកបង្គោលដីឡូត៍ដោយម្ចាស់ដីក្រោយមកក៏បានដាំបង្គោលឡើងវិញ ព្រោះមានការសម្រុះសម្រួលទ្វេរភាគីរវាង [redacted] **សុខុន** និងម្ចាស់ដី ([redacted] **គីម**, [redacted]**ហាន** និ[redacted]**អូល**) ដោយមានលិខិតសុំអភ័យទោសក្នុងការយឺតយ៉ាវបង់ថវិការបស់កូនក្តីយើងខ្ញុំឈ្មោះ [redacted] **សុខុន** ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ។

-នៅថ្ងៃទី១០ តុលា ឆ្នាំ២០១៧ កូនក្តីយើងខ្ញុំឈ្មោះ [redacted] **សុខុន** បានប្រគល់ទឹកប្រាក់បន្ថែមទៅឲ្យឈ្មោះ [redacted]**សុវណ្ណឌឿន** និងឈ្មោះ [redacted] **ម៉ាប់** ដែលតំណាងឲ្យម្ចាស់ដីឈ្មោះ [redacted]**គីម** ឈ្មោះ [redacted]**ហ៊ាន** និងឈ្មោះ [redacted]**អុល** នូវទឹកប្រាក់ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិក និងមានការបង់ប្រាក់បន្តបន្ទាប់ជាហូរហែរមក ។

ជាសរុបមក កូនក្តីយើងខ្ញុំបានប្រគល់ប្រាក់បន្តបន្ទាប់ រហូតដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ ឲ្យម្ចាស់ដីដើមរួចរាល់សរុបមានចំនួន ១០១.២០០ (មួយសែនមួយពាន់ពីររយ) ដុល្លាអាមេរិក ក្នុងនោះបានបង់ប្រាក់ឲ្យឈ្មោះ [redacted]**ហ៊ាន** ចំនួន ៣៥.៥០០ (បីម៉ឺនប្រាំពាន់ប្រាំរយ) ដុល្លាអាមេរិក, បានបង់ប្រាក់ឲ្យឈ្មោះ [redacted]**អុល** ៣៤.២០០ (បីម៉ឺនបួនពាន់ពីររយ) ដុល្លារអាមេរិក និងបានបង់ប្រាក់ឲ្យឈ្មោះ [redacted]**គីម** ចំនួន ៣១.៥០០ (បីម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ។

**សូមបញ្ជាក់ថា ៖**

១.តម្លៃដីជាក់ស្តែង ដែលកូនក្តីយើងខ្ញុំបានទិញពីឈ្មោះ [redacted] **គីម** ក្នុងមួយម៉ែត្រក្រឡា ៥,២០ (ប្រាំក្បៀសពីរកាក់) ដុល្លារអាមេរិក គុណនឹងផ្ទៃដីទំហំ ១៨.៣៣៧ ម៉ែត្រក្រឡា ស្មើនឹងទឹកប្រាក់ចំនួន ៩៥.៣៥២ (ប្រាំបួនម៉ឺនប្រាំពាន់បីរយហាសិបពីរ) ដុល្លាអាមេរិក ។ ដូច្នេះ [redacted]**សុខុន** បានទូទាត់រួចហើយអស់ចំនួន ៣១.៥០០ (បីម៉ឺនមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ទឹកប្រាក់ដែលនៅជំពាក់ [redacted] **គីម** ជាក់ស្តែងគឺចំនួន ៦៣.៨៥២ (ប្រាំមួយម៉ឺនបីពាន់ប្រាំបីរយហាសិបពីរ) ដុល្លារអាមេរិក ។

២.តម្លៃដីជាក់ស្តែងដែលកូនក្តីយើងខ្ញុំបានទិញពីឈ្មោះ [redacted]**ហ៊ាន** ក្នុងមួយម៉ែត្រក្រឡា ៤.៥០ (បួនក្បៀសហាសិប) ដុល្លារអាមេរិក គុណនឹងផ្ទៃដីទំហំ ១៥.៨៥៨ ម៉ែត្រក្រឡា ស្មើនឹងទឹកប្រាក់ចំនួន ៧១.៣៦១ (ប្រាំពីរម៉ឺនមួយពាន់បីរយហុកសិបមួយ) ដុល្លារអាមេរិក ។ ដូច្នេះ [redacted]**សុខុន** បានទូទាត់រួចហើយអស់ចំនួន ៣៥.៥០០ (បីម៉ឺនប្រាំពាន់



Scanned with CamScanner

ប្រាំរយ) ដុល្លារអាមេរិក ។ ទឹកប្រាក់ដែលនៅជំពាក់ [redacted] ហ៊ិន ជាក់ស្តែងគឺចំនួន ៤០.៨៦១ (បួនម៉ឺនប្រាំបីរយហុកសិប) ដុល្លារអាមេរិក ។

៣.តម្លៃដីជាក់ស្តែងដែលកូនក្តីយើងខ្ញុំបានទិញពីឈ្មោះ [redacted] អុល ក្នុងមួយម៉ែត្រក្រឡា ៤.៥០ (បួនក្បៀសហាសិប) ដុល្លារអាមេរិក គុណនឹងផ្ទៃដីទំហំ ១៤.៣៦៨ ម៉ែត្រក្រឡា ស្មើនឹងទឹកប្រាក់ចំនួន ៦៤.៦៥៦ (ប្រាំមួយម៉ឺនបួនពាន់ប្រាំមួយរយហាសិបប្រាំមួយ) ដុល្លារអាមេរិក ។ ដូច្នេះ [redacted] សុខុន បានសងប្រាក់អស់ចំនួន ៣៤.២០០ (បីម៉ឺនបួនពាន់ពីររយ) ដុល្លារអាមេរិក ។ ទឹកប្រាក់ដែលនៅជំពាក់ [redacted] អុល ជាក់ស្តែងគឺចំនួន ៣០.៤៥៦ (បីម៉ឺនបួនពាន់ពីររយ) ដុល្លារអាមេរិក ។

សរុបទឹកប្រាក់នៅជំពាក់ម្ចាស់ដើមទាំងបីនាក់គឺ ៖ ៦៣.៨៥២+ ៤០.៨៦១+៣០.៤៥៦=១៣៥.១៦៩ (មួយសែនបីម៉ឺនប្រាំពាន់មួយហុកសិបប្រាំបួន) ដុល្លារអាមេរិក ។

-នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ កូនក្តីយើងខ្ញុំឈ្មោះ [redacted] សុខុន ក៏បានធ្វើកិច្ចសន្យាមួយទៀត រវាងម្ចាស់ដីឈ្មោះ [redacted] អុល ឈ្មោះ [redacted] គីម និងឈ្មោះ [redacted] ហ៊ិន ដោយកិច្ចសន្យាបានចែងមាន៤ ចំណុចសំខាន់ៗគឺ ៖

១.ភាគីទិញ សូមសន្យាប្រគល់ប្រាក់ចំនួនថ្លៃទិញនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ។

២.បើផុតកំណត់ មិនគោរពតាមកិច្ចសន្យា ភាគីទិញដីយល់ព្រមយកប្លង់ដីដែលបានផ្ទេររួចហើយ ប្រគល់ជូនម្ចាស់ដីវិញ និងអាជ្ញាធរឃុំស្រុកមានសិទ្ធិធ្វើមោឃភាពលើការផ្ទេរសិទ្ធិដោយគ្មានការតវ៉ា ។

៣.ប្រាក់កក់កន្លងមកទុកជាអសារបង់ ។

៤.សំណូមពរភាគីម្ចាស់ដីកុំធ្វើឲ្យមានភាពរាំងស្ទះដល់ការលក់ដីឡូតិ៍ ។

ទោះជាយ៉ាងនេះក្តី នៅអំឡុងខែធ្នូ ឆ្នាំ២០១៧ ដោយមិនទាន់បានផុតកំណត់កិច្ចសន្យាផង ភាគីម្ចាស់ដីមិនបានគោរពទៅតាមកិច្ចសន្យានូវចំណុចលេខ ៤ ហើយបានវាយបង្គោលដីឡូតិ៍ចោល និងបានសរសេរអក្សរពណ៌ក្រហមហាមមិនឲ្យទិញលក់ព្រមទាំងបានជីកប្រឡាយកាត់ផ្លូវមិនឲ្យចូលតំបន់ដីឡូតិ៍ ។ ថែមពីលើនោះទៀត ភាគីម្ចាស់ដីរួមជាមួយបក្សពួកប្រមាណប្រហែល ១០នាក់ បានធ្វើរបងបិទផ្លូវមិនឲ្យចូលដីឡូតិ៍ ព្រមទាំងមានការគ្រៀមដេញកាប់ភាគីអ្នកទិញដីឡូត៍ទៀតផង ពេលដែលភាគីទិញដីឡូតិ៍បានចូលទៅមើលដីរបស់ពួកគាត់ ។ ក្រៅពីនោះទៀត កូនស្រីរបស់ឈ្មោះ [redacted] គីម (មិនស្គាល់ឈ្មោះ) បានចុះទៅដកបង្គោល និងវាយបង្គោលចោលជាបន្តបន្ទាប់ ។

ក្រោយមក នៅអំឡុងខែមករាទៅខែមីនា ឆ្នាំ២០១៨ មានការប្តឹងទៅសាលាឃុំទួលព្រេជ រហូតដល់សាលាស្រុកអង្គស្នួលដោយភាគីម្ចាស់ដី ពេលនោះក៏មានការកោះហៅដើម្បីធ្វើការសម្រុះសម្រួលផងដែរ ដោយកូនក្តីយើងខ្ញុំឈ្មោះ [redacted] សុខុន ជាប់មមាញឹកការងារខាងក្រៅ និងដោយសារតែប្រពន្ធរបស់គាត់មានបញ្ហាសុខភាពក៏ត្រូវនាំប្រពន្ធទៅព្យាបាលនៅប្រទេសថៃផង ដូច្នេះពុំអាចចូលរួមដោយផ្ទាល់ ក៏បានចាត់តំណាងក្រុមហ៊ុនចូលរួមក្នុងកិច្ចសម្រុះសម្រួលទាំងនៅសាលាឃុំ និងសាលាស្រុក ។ ជាលទ្ធផលនៃការសម្រុះសម្រួល គឺពុំមានលទ្ធផលជាវិជ្ជមាន ។ ក្រោយមកក៏មានការប្តឹងទៅសាលាដំបូងខេត្តកណ្តាល ដោយម្ចាស់ដីដើម្បីស្នើសុំឲ្យចេញដីកាសម្រេចរក្សាការពារ រហូតបន្តមកដល់អង្គសេចក្តីនាពេលបច្ចុប្បន្ននេះ នៅសាលាដំបូងខេត្តកណ្តាល។



Scanned with CamScanner

**បញ្ជាក់** ៖ នៅអំឡុងឆ្នាំ២០១៨នោះដែរ ពេលត្រឡប់មកពីនាំប្រពន្ធទៅព្យាបាលនៅប្រទេសថៃ កូនក្ដីយើងខ្ញុំក៏ត្រូវបានសមត្ថកិច្ចរាជធានីភ្នំពេញឃាត់ខ្លួន ព្រោះមានវិវាទជាមួយធនាគារ [redacted] **សុខុន** ក៏ត្រូវបានឃុំខ្លួន និងត្រូវបានតុលាការសាលាដំបូងរាជធានីភ្នំពេញ ប្រកាសទោស និងដាក់ពន្ធនាគារ PJ រហូតមកដល់ពេលបច្ចុប្បន្ន ដែលជាហេតុចម្បងធ្វើឲ្យកូនក្ដីយើងខ្ញុំពុំមានឱកាសគ្រប់គ្រាន់ក្នុងការចេញមុខដោះស្រាយបញ្ហាជាមួយ [redacted] **ហ៊ាន** ឈ្មោះ [redacted] **គីម** និងឈ្មោះ [redacted] **អុល** ។

ទោះជាយ៉ាងណាក្ដី នៅអំឡុងដើមឆ្នាំ ២០១៨ ពេលនោះ ឈ្មោះ [redacted] **សុខុន** កំពុងស្ថិតនៅពន្ធនាគារ ក្រុមភាគីអ្នកទិញដីឡូតិ៍ ក៏បានចេញមុខធ្វើការសម្រុះសម្រួលជាមួយម្ចាស់ដី បានយកថវិកាទៅសងតាមដំណាក់កាលដោយលើកទី១.មានចំនួនថវិកាប្រមាណជា ១៤.៥០៨ (មួយម៉ឺនបួនពាន់ប្រាំរយប្រាំបី) ដុល្លារអាមេរិក ជូនម្ចាស់ដី និងលើកទី២.នៅដើមឆ្នាំ២០២០ នៅចំនួនថវិកា ៥០.១៩៦ (ប្រាំម៉ឺនមួយរយកៅសិបប្រាំមួយ) ដុល្លារអាមេរិក ជូនម្ចាស់ដី តែពួកគាត់មិនព្រមទទួល ដោយទាមទារយកតម្លៃថ្មីស្មើនឹង ៦ (ប្រាំមួយ) ដុល្លារអាមេរិកក្នុងមួយម៉ែត្រក្រឡា ។

**សូមបញ្ជាក់ថា៖** ការសម្រុះសម្រួល និងប្រគល់ជូនថវិកាលើកទី២នោះ គឺភាគីឈ្មោះ [redacted] **គីម** បានព្រមព្រៀងជាមួយភាគីក្រុមអ្នកទិញដីឡូតិ៍រួចហើយថានឹងទទួលយកថវិកា ៥០.១៩៦ (ប្រាំម៉ឺនមួយរយកៅសិបប្រាំមួយ) ដុល្លារអាមេរិក តែពេលនាំគ្នាទៅដល់សាលាឃុំទួលព្រេជ ដើម្បីប្រគល់ និងទទួលប្រាក់ ឈ្មោះ [redacted] **គីម** បានបដិសេធមិនទទួលទៅវិញ ។

**ដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅតុលាការ៖**

**ដំណាក់កាលទី១៖** កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមសាលាដំបូងខេត្តកណ្ដាល អំពីសំណុំរឿងប្ដឹងសុំឲ្យចុងចម្លើយផ្ទេរកម្មសិទ្ធិ ដែលប្ដឹងដោយឈ្មោះ [redacted] **អុល** ឈ្មោះ [redacted] **គីម** និងឈ្មោះ [redacted] **ហ៊ាន** បានទាមទារឲ្យកូនក្ដីយើងខ្ញុំឈ្មោះ [redacted] **សុខុន** ផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុមកឲ្យខ្លួនវិញ និងសុំរំលាយកិច្ចសន្យាលក់ទិញដី ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ។ នីតិវិធីត្រៀមដោយអវត្តមានកូនក្ដីយើងខ្ញុំ ។

**ដំណាក់កាលទី២៖** កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមសាលាដំបូងខេត្តកណ្ដាល ពាក់ព័ន្ធនឹងសំណុំរឿងដូចក្នុងដំណាក់កាលទី១ ។ នីតិវិធីត្រៀមកូនក្ដីយើងខ្ញុំបានស្នើឲ្យតុលាការដាក់កម្មវិធី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកក្រោយ ដើម្បីទុកឱកាសរកមេធាវីដើម្បីដោះស្រាយរឿងក្ដី ។

**ដំណាក់កាលទី៣៖** កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមសាលាដំបូងខេត្តកណ្ដាល ពាក់ព័ន្ធនឹងសំណុំរឿងដូចក្នុងដំណាក់កាលទី១ និងទី២ ។ នីតិវិធីត្រៀម កូនក្ដីយើងខ្ញុំបានថ្លែងការណ៍ថា គាត់កំពុងត្រៀមរៀបចំប្រាក់សងទៅសបាដើមចោទ និងស្វែងរកដំណោះស្រាយនៅតុលាការលើកក្រោយ។



Scanned with CamScanner

៤.ចំណុចវិវាទ៖ សហដើមចោទសុំឲ្យតុលាការសម្រេចរំលាយកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] ម៉ាច់ និងឈ្មោះ [redacted] វណ្ណឌឿន (តំណាងឲ្យទាំងបីគ្រួសារ) ជាមួយនិងឈ្មោះ [redacted] ប៊ុនធឿន (តំណាងឲ្យឈ្មោះ [redacted] សុខុន) តែចុងចម្លើយសូមឲ្យបន្តកិច្ចសន្យានេះ ។

**៥.ចំណុចគ្មានវិវាទ៖** ពិតជាមានការបង្កើតកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] ម៉ាច់ និងឈ្មោះ [redacted] វណ្ណឌឿន (តំណាងឲ្យទាំងបីគ្រួសារ) ជាមួយនិងឈ្មោះ [redacted] ប៊ុនធឿន (តំណាងឲ្យឈ្មោះ [redacted] សុខុន) ពិតប្រាកដមែន ។

**៦.ភស្តុតាងជាឯកសារ ៖**

-កិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] ម៉ាច់ និងឈ្មោះ [redacted] វណ្ណឌឿន (តំណាងឲ្យទាំងបីគ្រួសារ) ជាមួយនិងឈ្មោះ [redacted] ប៊ុនធឿន (តំណាងឲ្យឈ្មោះ [redacted] សុខុន) ។

-ច្បាប់ថតចម្លងលិខិតផ្ទេរសិទ្ធិកាន់កាប់អចលទ្រព្យដែលមិនទាន់ចុះបញ្ជី កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយមេឃុំទួលព្រេជលេខ ១២២៤/១៧ ទ.ព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយអភិបាលស្រុកអង្គស្នួលលេខ ៨៩៨/១៧ បផ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ដោយមានភ្ជាប់ជាមួយគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួល ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ដោយសាលាឃុំទួលព្រេជ ។

-ច្បាប់ថតចម្លងលិខិតផ្ទេរសិទ្ធិកាន់កាប់អចលទ្រព្យដែលមិនទាន់ចុះបញ្ជី កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយមេឃុំទួលព្រេជលេខ ១២៣០/១៧ ទ.ព ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយអភិបាលស្រុកអង្គស្នួលលេខ ១៨៥៥/១៧ បផ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដោយមានភ្ជាប់ជាមួយគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួល ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ដោយសាលាឃុំទួលព្រេជ ។

-ច្បាប់ថតចម្លងលិខិតផ្ទេរសិទ្ធិកាន់កាប់អចលទ្រព្យដែលមិនទាន់ចុះបញ្ជី កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយមេឃុំទួលព្រេជលេខ ១៥៩១/១៧ ទ.ព ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ និងបានឃើញ និងឯកភាពដោយអភិបាលស្រុកអង្គស្នួលលេខ ១៤៨៧/១៧ បផ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ដោយមានភ្ជាប់ជាមួយគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួល ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ដោយសាលាឃុំទួលព្រេជ ។

-ច្បាប់ថតចម្លងលិខិតសុំអភ័យទោសរបស់ឈ្មោះ [redacted] សុខុន និងប្រពន្ធឈ្មោះ [redacted] គីមមុនី ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ។

-កិច្ចសន្យារបស់ឈ្មោះ [redacted] សុខុន និងប្រពន្ធឈ្មោះ [redacted] គីមមុនី រវាងឈ្មោះ [redacted] គីម ឈ្មោះ [redacted] អុល និងឈ្មោះ ឌី ហាន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

-ប្លង់ទីតាំងដីឡូតិ៍ ដែលឈ្មោះ [redacted] សុខុន បានពុះលក់នៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

-តារាងរាយនាម និងស្នាមមេដៃប្រជាពលរដ្ឋជាង ២០០ នាក់ ដែលបានទិញដីឡូតិ៍របស់ក្រុមហ៊ុន [redacted] សុខុន ដែលមានទីតាំងនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

-លិខិតបញ្ជាក់ដីធ្លីរបស់សាលាឃុំទួលព្រេជ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ។



Scanned with CamScanner

-លិខិតបញ្ជាក់ពីធនាគារស្តីពីឈ្មោះ [redacted] សុខុន ពិតជាបានដាក់បញ្ចាំនូវលិខិតកាន់កាប់អចលនវត្ថុទ្រព្យ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ។

## សំអាងហេតុ

១.សហដើមចោទឈ្មោះ [redacted] អុល និងប្រពន្ធឈ្មោះ [redacted] ស៊ីថា, ឈ្មោះ [redacted] គឹម ប្រពន្ធឈ្មោះ [redacted] ទូច, និងឈ្មោះ [redacted] ហន ប្រពន្ធឈ្មោះ [redacted] អ៊ឹម បានដាក់ពាក្យបណ្តឹង និងថ្លែងទាមទារសុំឲ្យតុលាការចេញសាលក្រមសម្រេច៖ ទី១.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុខុម ផ្ទេរសិទ្ធិកាន់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១២២៤/១៧ ទ.ព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទូលទំហំ ១៤.៣៦៤ (បួយម៉ឺនបួនពាន់បីរយហុកសិបប្រាំបី) ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទូលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល មកឲ្យសហដើមចោទឈ្មោះ [redacted] អុល និងប្រពន្ធឈ្មោះ [redacted] ស៊ីថា វិញ ។ ទី២.បង្គាប់ឲ្យចុងចម្លើយ [redacted] សុខុន ផ្ទេរសិទ្ធិកាន់កាប់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១២៣០/១៧ ទ.ព ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទូលទំហំ ១៨.៣៣៧ (មួយម៉ឺនប្រាំពាន់បីរយសាមសិបប្រាំពីរ) ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទូលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល បកឲ្យសហដើមចោទឈ្មោះ [redacted] គឹម និងប្រពន្ធឈ្មោះ [redacted] ទូច វិញ ។ ទី៣.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុខុន ផ្ទេរសិទ្ធិកាន់កាប់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១៥៩១/១៧ ទ.ព ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទូលទំហំ ១៥.៨៥៨ (មួយម៉ឺនប្រាំពាន់ប្រាំបីរយហាសិបប្រាំបី) ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទូលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល បកឲ្យសហដើមចោទឈ្មោះ [redacted] ហ៊ន និងប្រពន្ធឈ្មោះ [redacted] អ៊ឹម វិញ ។ ទី៤.រំលាយកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧ រវាងឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] វណ្ណឿន (តំណាងឲ្យទាំង៣គ្រួសារ) ជាមួយឈ្មោះ [redacted] ប៊ុនធឿន (តំណាងឲ្យឈ្មោះ [redacted] សុខុន) ។ ទី៥.សងសេវាកម្មច្បាប់ និងជម្ងឺចិត្តចំនួន ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល ។ និងទី៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។ ដោយសហដើមចោទអះអាងថាកាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ចុងចម្លើយបានចុះកិច្ចសន្យាទិញដី (តាមរយៈអ្នកតំណាង) និងបានកក់ប្រាក់ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក និងលើកទី២ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ កក់ប្រាក់បន្ថែមចំនួន ២១.០០០ (ពីរម៉ឺនមួយពាន់) ដុល្លារអាមេរិក និង២០ (ម្ភៃ)ថ្ងៃបន្ទាប់ទៀតកក់ប្រាក់បន្ថែមចំនួន ៣៥.០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក និងសន្យាប្រគល់ប្រាក់ថ្លៃដីឲ្យគ្រប់ចំនួននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ ។ លុះដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] សុខុន មិនបានប្រគល់ប្រាក់បង្គ្រប់ថ្លៃដីនោះឲ្យពួកខ្លួនទេ រហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ទើបប្រគល់ប្រាក់ឲ្យពួកខ្លួនចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ។ ហើយបន្ទាប់មកទៀតនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ឈ្មោះ [redacted] សុខុន បានប្រគល់ប្រាក់ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិកបន្ថែមទៀតឲ្យពួកខ្លួន និងបានធ្វើកិច្ចសន្យាថានឹងប្រគល់ប្រាក់ថ្លៃដីឲ្យគ្រប់ចំនួននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ ។ ប៉ុន្តែដល់ថ្ងៃកំណត់ចុងចម្លើយឈ្មោះ [redacted] សុខុន មិនបានអនុវត្តតាមកិច្ចសន្យានោះទេ ។

២.ចុងចម្លើយឈ្មោះ [redacted] សុខុន បានអះអាងថា ខ្លួនពិតជាបានចុះកិច្ចសន្យាទិញដីពីសហដើមចោទពិតមែន (តាមរយៈអ្នកតំណាង) ហើយនិងបានប្រគល់ប្រាក់ថ្លៃដីឲ្យសហដើមចោទជាបន្តបន្ទាប់សរុបបានចំនួន ១០១.២០០ (មួយសែនមួយពាន់ពីររយ) ដុល្លារអាមេរិក នៅខ្វះចំនួន ១៣៥.១៦៩ (មួយសែនបីម៉ឺនប្រាំពាន់មួយរយហុកសិបប្រាំបួន) ដុល្លា-អាមេរិក ។ ដោយសារតែខ្លួនជាប់រវល់ជូនប្រពន្ធទៅព្យាបាលជំងឺនៅប្រទេសថៃ ហើយត្រលប់មកវិញត្រូវបានតុលាការរាជ



Scanned with CamScanner

ធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគាររាជធានីភ្នំពេញ (PJ) ធ្វើឲ្យខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីដោះស្រាយប្រាក់ថ្លៃដីដែលនៅសល់ជាមួយសហដើមចោទបាន ។

៣.តាមការអះអាងរបស់សហដើមចោទ ចុងចម្លើយ និងឯកសារ កិច្ចសន្យាលក់ដី ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ និងកិច្ចសន្យាចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ឃើញថាសហដើមចោទ និងចុងចម្លើយ ពិតជាបានចុះកិច្ចសន្យាទិញលក់ដី (តាមរយៈអ្នកតំណាង) ប្រាកដមែន ហើយចំពោះការទាមទាររបស់សហដើមចោទធ្វើឡើងស្របតាមកិច្ចសន្យាលក់ដី ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ ។ ចំណែកចុងចម្លើយឈ្មោះ [redacted] សុខុន ដែលបានបញ្ជាក់ថាខ្លួនខកខានមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យានោះ ដោយសារតែខ្លួនជាប់រវល់ជូនប្រពន្ធទៅព្យាបាលជំងឺនៅប្រទេសថៃ និងពេលត្រលប់មកវិញត្រូវតុលាការរាជធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគាររាជធានីភ្នំពេញ (PJ) ។ ឃើញថាមូលហេតុដែលចុងចម្លើយបានលើកឡើងគឺមិនស្របតាមច្បាប់នោះទេ ។ ដូចនេះតុលាការគប្បីពិចារណា និងសម្រេចតាមការទាមទាររបស់សហដើមចោទ ។

៤.ប្រាក់ប្រដាប់ក្តីអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១.ទទួលស្គាល់ពាក្យបណ្តឹង និងការទាមទាររបស់សហដើមចោទ៖

ក.ឈ្មោះ [redacted] អុល ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] ស៊ីថា អាយុ៥០ឆ្នាំ ទីលំនៅបច្ចុប្បន្ន [redacted] ។

ខ.ឈ្មោះ [redacted] គឹម ភេទប្រុស អាយុ៦០ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] ទូច ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ។

គ.ឈ្មោះ [redacted] ហ៊ិន ភេទប្រុស អាយុ៥៧ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] អ៊ីម ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ។

*ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ។*

២.រំលាយកិច្ចសន្យាលក់ដី ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] សុវណ្ណឌឿន (តំណាងឲ្យទាំង៣គ្រួសារ) ជាមួយនិងឈ្មោះ [redacted] ប៊ុនធឿន (តំណាងឲ្យឈ្មោះ [redacted] សុខុន) ។

៣.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុខុន ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅ [redacted] ៖

៣/១.ផ្ទេរសិទ្ធិកាន់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១២២៤/១៧ ទ.ព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួលទំហំ ១៤.៣៦៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ឲ្យទៅសហដើមចោទឈ្មោះ [redacted] អុល និងប្រពន្ធឈ្មោះ [redacted] ស៊ីថា វិញ ។

៣/២.ផ្ទេរសិទ្ធិកាន់កាប់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១២៣០/១៧ ទ.ព ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួលទំហំ ១៨.៣៣៧ ម៉ែត្រក្រឡា ស្ថិតនៅភូមិ



Scanned with CamScanner

ត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុករវៀងស្នួល ខេត្តកណ្តាល ឲ្យទៅសហដើមចោទឈ្មោះ [redacted] គីម និងប្រពន្ធឈ្មោះ [redacted] ទូច វិញ ។

៣/៣.ផ្ទេរសិទ្ធិកាន់កាប់ចំពោះអចលនទ្រព្យដែលមិនទាន់ចុះបញ្ជីលេខ ១៥៩១/១៧ ទ.ព ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ ដែលមានគំនូសបង្ហាញទីតាំងអចលនទ្រព្យដីទួលទំហំ ១៥.៨៥៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិត្រពាំងកំភ្លាញ ឃុំទួលព្រេជ ស្រុករវៀងស្នួល ខេត្តកណ្តាល ឲ្យទៅសហដើមចោទឈ្មោះ [redacted] ហ៊ាន និងប្រពន្ធឈ្មោះ [redacted] អ៊ីម វិញ ។

៤.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុខុន សងសេវាកម្មច្បាប់ និងជម្ងឺចិត្តចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅឲ្យសហដើមចោទឈ្មោះ [redacted] រុល និងប្រពន្ធឈ្មោះ [redacted] ស៊ីថា, ឈ្មោះ [redacted] គីម និងប្រពន្ធឈ្មោះ [redacted] ទូច, និងឈ្មោះ ឌី ហាន និងប្រពន្ធឈ្មោះ [redacted] អ៊ីម ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខសហដើមចោទ និងចុងចម្លើយ ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤

ធ្វើនៅខេត្តកណ្តាល ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner